

**ថ្ងៃទី២៩ខែតុលានេះ គឺជាខួបលើកទី១៦នៃការឡើងគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ មក។ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ បានណែនាំ ឲ្យក្រសួងព្រះបរមរាជវាំង រៀបចំព្រះរាជពិធីបុណ្យខួបលើកទី១៦ នៃទិវាគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះមហាក្សត្រ នៅក្នុងព្រះបរមរាជវាំង។**

ព្រះអង្គ នរោត្តម សីហមុនី ទ្រង់បានប្រសូតនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៥៣ នៅរាជធានីភ្នំពេញ។ ព្រះអង្គបានទទួលការអប់រំថ្នាក់បឋមសិក្សានៅសាលានរោត្តម វិទ្យាល័យដេកាតភ្នំពេញ នៅក្នុងឆ្នាំ១៩៥៩ ដល់ឆ្នាំ ១៩៦២។ បន្ទាប់ពី នោះ មកព្រះអង្គក៏បានទទួល ការសិក្សាអប់រំនៅវិទ្យាល័យប្រាគ នៅសាធារណរដ្ឋឆែក រហូតដល់ឆ្នាំ១៩៧៥។ នៅទីនោះព្រះអង្គបានសិក្សាជំនាញផ្នែករបាំបុរាណ នៅវិទ្យាស្ថានអភិរក្សជាតិប្រាគ ហើយព្រះអង្គក៏ទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ នៃបណ្ឌិតសភាផ្នែកសិល្បៈតន្ត្រីប្រាគ។ រួចមកព្រះអង្គក៏បានបន្តឧត្តមសិក្សាខាងផ្នែកភាពយន្តរយៈពេល១ឆ្នាំ នៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េផងដែរ។

ដោយឡែកនៅឆ្នាំ១៩៧៦ ដល់១៩៧៩ ព្រះអង្គសីហមុនី បានជាប់ក្រោមការឃុំឃាំង របស់ខ្មែរក្រហម ជាមួយនឹងព្រះវររាជបិតា និងព្រះវររាជមាតា និងព្រះអនុជ សម្តេច នរោត្តម នរិន្ទ្រៈពង្ស។ បន្ទាប់ពីរបបខ្មែរក្រហមមក នៅក្នុងឆ្នាំ១៩៨០ ព្រះអង្គបានក្លាយជាព្រះរាជលេខាផ្ទាល់ របស់ព្រះបិតានរោត្តមសីហនុ នៅពេលដែលព្រះអង្គគង់ប្រថាប់នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន។

លុះបន្តបន្ទាប់មក ព្រះអង្គនរោតម្តសីហមុនី បានបន្តការងាររបស់ព្រះអង្គក្នុងវិស័យសិល្បៈជាច្រើន រហូតបានក្លាយជា ប្រធានសមាគមរបាំខ្មែរនៅប្រទេសបារាំង និងជាអគ្គនាយក ព្រមទាំងជានាយកសិល្បៈនៃក្រុមរបាំបាលេ DEVA។ ព្រះអង្គក៏បានបង្កើតស្នាព្រះសហស្ថផលិតខ្សែភាពយន្តរបាំបាលេ ចំនួនពីរ គឺមានរឿង សុបិន្ត និងរឿងធាតុទាំង៤។

គិតមកដល់ពេលនេះ គឺរយៈពេល១៥ឆ្នាំគត់នៃការឡើងសោយរាជ្យរបស់ព្រះអង្គ។ ក្នុងរយៈពេល ១៦ឆ្នាំមកនេះ ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ត្រូវបានប្រជានុរាស្ត្រលើកសរសើរទ្រង់ថា ជាព្រះមហាក្សត្រដែលមានព្រះទ័យស្លូតបូត និងមានព្រហ្មវិហារធម៌។ ជាមួយគ្នានេះ ពួកគេក៏បានកោតសរសើរទ្រង់ផងដែរដែលបានបំពេញព្រះរាជកិច្ចសម្រាប់ប្រជាជាតិ ប្រកបដោយភាពវិជ្ជ

មាន។ ព្រះរាជកិច្ចសំខាន់ៗរបស់ទ្រង់ គឺផ្តោតលើវិស័យពិធីការ ការទូត សង្គមកិច្ច វប្បធម៌ និងសិល្បៈ ដែលព្រះរាជសកម្មភាពទាំងនេះ ដូចគ្នាទៅនឹងអ្វីដែលព្រះបិតារបស់ទ្រង់ គឺព្រះបរមរតនកោដ្ឋ ធ្លាប់បានបំពេញផងដែរ។

ព្រះអង្គបានបន្តការងារជាច្រើននៅក្នុងប្រទេសរហូតដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ ព្រះអង្គត្រូវបានសមាជិកក្រុមប្រឹក្សារាជសម្បត្តិជ្រើសរើសជាឯកច្ឆន្ទជា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រហូតមកទល់នឹងបច្ចុប្បន្ននេះ។ ព្រះអង្គចេះប្រើភាសាចំនួនបី គឺបារាំង អង់គ្លេស និងឆេក ហើយព្រះអង្គក៏ទទួលបានគ្រឿងឥស្សរិយយសជាច្រើនផងដែរដែលរួមមានទាំងជាតិនិងអន្តរជាតិ៕

ដកស្រង់ចេញពីគេហទំព័រ RFI